ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦

# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិលើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី

## សន្ទរកថាស្វាគមន៍

## ដោយ

## លោកស្រី វ៉ាន់-ហ៊ី លី តំណាងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា

សូមគោរព ឯកឧត្តម ស៊ិក ប៊ុនហុក ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំរៀបចំការបោះឆ្នោតដ៏ចំណាន១
ឯកឧត្តម លោកជំទាវដែលអញ្ជើញមកពីសហគមន៍ទូត និងសហគមន៍ម្ចាស់ជំនួយ
សមាជិកគណៈបក្សនយោបាយ និងសង្គមស៊ីវិលនានា
អស់លោក លោកស្រីអ្នកនាងកញ្ញាជាទីរាប់អាន

ថ្ងៃនេះ ខ្ញុំមានកិត្តិយសសូមស្វាគមន៍អ្នកទាំងអស់គ្នាដែលមានវត្តមាននៅទីនេះ។ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មានសេចក្តីសោមនស្សរីករាយសូមគាំទ្រគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលប្រារព្វធ្វើកិច្ចប្រជុំនេះ ដោយឆ្ពោះទៅរកការអនុវត្តនូវសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការបោះឆ្នោត និងចូលរួមក្នុងការដឹកនាំកិច្ចការសាធារណៈ, សិទ្ធិមនុស្សសំខាន់ចំនួនពីរដែលបានធានានៅក្រោម កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាក៏ជាភាគីមួយផងដែរ។

ចំណាប់អារម្មណ៍របស់អង្គការសហប្រជាជាតិក្នុងការមើលឃើញប្រព័ន្ធបោះឆ្នោតល្អមួយដែលបានបង្កើតឡើងនៅកម្ពុជា អាចត្រូវបានឆ្លុះបញ្ចាំងទៅនឹងការបោះឆ្នោតជាលើកដំបូងដែលរៀបចំនៅឆ្នាំ ១៩៩៣ ក្រោមការទំនុកបម្រុងរបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ឬអ៊ុនតាក់។ នៅពេលនោះ ប្រធានស៊ីវិលនៃអ៊ុនតាក់គឺ លោក អាកាស៊ី យាស៊ូស៊ី បានពន្យល់ថា "អ៊ុនតាក់គឺនៅទីនេះ" ហើយមានប្រសាសន៍ថា "ដើម្បីជួយប្រជាជនកម្ពុជាអនុវត្តសិទ្ធិធិបតេយ្យពេញលេញរបស់ពួកគេ ដោយគោរពនូវសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ"។ ម្ភៃបីឆ្នាំកន្លងផុតទៅហើយ វាជារយៈពេលដ៏យូរបន្ទាប់ពីប្រតិបត្តិការរបស់អ៊ុនតាក់បានបញ្ចប់ អង្គការសហប្រជាជាតិនៅតែចង់ឃើញប្រជាជនកម្ពុជាអនុវត្តនូវសិទ្ធិប្រជាធិបតេយ្យរបស់គេបានពេញលេញ ដោយគោរពនូវសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

គោលដៅចុងក្រោយគឺរៀបចំការបោះឆ្នោតដែលគួរឲ្យទុកចិត្ត និងប្រកបដោយសន្តិវិធី ដែលអ្នកមានសិទ្ធិបោះឆ្នោតទាំងអស់អាចចូលរួមបាន, បេក្ខជនឈរឈ្មោះទាំងអស់អាចធ្វើយុទ្ធនាការដោយគ្មានការភ័យខ្លាចឬរាំងស្ទះ ហើយលទ្ធផលនៃការបោះឆ្នោតអាចទទួលយកបានយ៉ាងទូលំទូលាយ។ លោកអគ្គលេខាធិការអង្គ

ការសហប្រជាជាតិបានបញ្ជាក់បញ្ហានេះនៅក្នុងរបាយការណ៍ចុងក្រោយរបស់លោកស្តីពីការបោះឆ្នោតដាក់ជូនមហាសន្និបាត (A/70/306)៖ ភាពជឿជាក់បាននៃការបោះឆ្នោតមួយ "គឺមានការពាក់ព័ន្ធទៅនឹងកម្រិតនៃការគោរពនូវកាតព្វកិច្ចអន្តរជាតិទាំងពីរ ហើយដំណើរការបោះឆ្នោតប្រកបដោយលក្ខណៈវិជ្ជាជីវៈ, មានភាពត្រឹមត្រូវ, មិនលំអៀង និងមានតម្លាភាពគ្រប់ដំណាក់កាលទាំងអស់នៃការគ្រប់គ្រងបោះឆ្នោត"។ លោកក៏បានមានប្រសាសន៍បន្តទៀតថា "ការបោះឆ្នោតដ៏ពិតប្រាកដមួយគឺជាការបោះឆ្នោតដែលលទ្ធផលឆ្លុះបញ្ចាំងពីជម្រើសដោយសេរី ឬជម្រើសនានារបស់អ្នកបោះឆ្នោត ដូច្នេះហើយការបោះឆ្នោតពិតប្រាកដនោះអាចទទួលយកបានយ៉ាងទូលំទូលាយ"។ ដើម្បីឆ្ពោះទៅសម្រេចបានការបោះឆ្នោតដ៏ពិតប្រាកដនេះ ចាំបាច់ត្រូវមាន "ទាំងការកាត់បន្ថយនយោបាយអ្នកឈ្នះយកទាំងអស់ និងនយោបាយប្រជុយប្រជានខ្លាំង នៅក្នុងការបោះឆ្នោត ទាំងពង្រឹងនីតិវិធីផ្សេងៗដល់ការបោះឆ្នោតតែម្តង"។

ការអនុវត្តនូវ "សិទ្ធិប្រជាធិបតេយ្យពេញលេញ" ក្នុងការបោះឆ្នោតដែលគួរឲ្យជឿទុកចិត្តមួយបាន ត្រូវផ្តើមចេញពី បញ្ជីឈ្មោះបោះឆ្នោតដ៏ត្រឹមត្រូវមួយ។ ថ្ងៃនេះ យើងនឹងពិនិត្យមើលឡើងវិញអំពីរបៀបដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលនឹងធានាបានថាជនគ្រប់រូប និងជនទាំងឡាយដែលមានសិទ្ធិបោះឆ្នោត និងមានបំណងចង់អនុវត្តសិទ្ធិ ចុះឈ្មោះក្នុងបញ្ជី។ វាជាក់ច្បាស់ណាស់ថាជាការអនុវត្តដ៏ស្មុគស្មាញមួយនៅពេលដែលកិច្ចការនេះជាប់ពាក់ព័ន្ធនឹងមនុស្សរាប់លាននាក់នោះ។

ក្នុងន័យនេះ ខ្ញុំកត់សម្គាល់ដោយស្ងើចសរសើរចំពោះការជ្រោមជ្រែងរបស់សហភាពអឺរ៉ុប និងប្រទេសជប៉ុន ដែលកំពុងជួយ "សម្ភារគ្រឿងម៉ាស៊ីនសម្រាប់បម្រើការបោះឆ្នោត" ដល់ប្រទេសកម្ពុជាដើម្បីធ្វើទំនើបកម្មជាមួយនឹងបច្ចេកវិទ្យាថ្មី និងវិធីសាស្រ្តនានា ក្នុងពេលដ៏មមាញឹកនេះ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំ ដូចអ្នកទាំងអស់គ្នាដែរថា ប្រព័ន្ធថ្មីនេះនឹងឆ្លុះបញ្ចាំងពីការពិនិត្យយ៉ាងជិតដល់នូវពាក្យបណ្តឹងសំខាន់ៗដែលពាក់ព័ន្ធនឹងការបោះឆ្នោតជាតិឆ្នាំ ២០១៣ និងវិះរកមធ្យោបាយនានាដើម្បីបង្ការទប់ស្កាត់កុំឲ្យមានបញ្ហាទាំងនោះនាពេលអនាគតទៀត។

ក្នុងន័យនេះដែរ ខ្ញុំសូមរំលឹកម្តងទៀតថា ក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ៧០/១៦៨ មហាសន្និបាតអង្គការសហប្រជាជាតិ "(បាន)បញ្ជាក់ឡើងវិញនូវ តួនាទីរបស់សង្គមស៊ីវិល និងសារៈសំខាន់នៃការចូលរួមយ៉ាងសកម្មរបស់សង្គមស៊ីវិលក្នុងការលើកស្ទួយប្រជាធិបតេយ្យូបនីយកម្ម និង(បាន)ស្នើសុំរដ្ឋជាសមាជិកជួយសម្របសម្រួលឲ្យមានការចូលរួមយ៉ាងពេញលេញរបស់សង្គមស៊ីវិលនៅក្នុងដំណើរការបោះឆ្នោតនានា"។ កិច្ចប្រជុំថ្ងៃនេះជាការឆ្លើយតបទៅនឹងអនុសាសន៍អស់ទាំងនោះ។ ខ្ញុំទន្ទឹងរង់ចាំដោយក្តីសោមនស្សរីករាយនូវឱកាសនៃកិច្ចប្រជុំនេះ ដែលនឹងត្រូវប្រើដើម្បីពិនិត្យឡើងវិញយ៉ាងហ្មត់ចត់នូវសេចក្តីព្រាងបទបញ្ញា និងនីតិវិធីនានា ប្រសិនបើយល់ថាចាំបាច់ ត្រូវប្រើដើម្បីធ្វើឲ្យប្រសើរឡើងនូវសេចក្តីព្រាងបទបញ្ញា និងនីតិវិធី

ទាំងនោះ ដោយផ្អែកលើឧត្តមគតិរួម និងគោលដៅរួមរបស់អ្នកក្នុងការធ្វើឲ្យមានការបោះឆ្នោតដែលអាចជឿទុកចិត្តបាននៅឆ្នាំ ២០១៧ និងឆ្នាំ ២០១៨។

ដោយសម្លឹងមើលតទៅថ្ងៃអនាគត ខ្ញុំសូមរំលឹកនូវអនុសាសន៍របស់អតីតអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោកសាស្ត្រាចារ្យ សុរិយាស៊ូប៊ែឌី លើបញ្ហានៃការចុះឈ្មោះបោះឆ្នោត។ វិធានការដែលកំពុងតែយកមកដោះស្រាយនៅពេលបច្ចុប្បន្ននេះឃើញថាជាទីពេញចិត្តដែលយកមកដោះស្រាយដោយសមប្របកនូវកង្វល់របស់លោកនាពេលនោះ ដែលវិធានការទាំងនេះគឺការទប់ស្កាត់ការចេញ និងការប្រើប្រាស់នូវឯកសារអត្តសញ្ញាណក្លែងបន្លំ និងការផ្តល់ឯកសារកំណត់អត្តសញ្ញាណរបស់អ្នកបោះឆ្នោតត្រឹមត្រូវ។ លោកបានស្នើយោបល់បន្ថែមទៀតឲ្យធានាថា "ពលរដ្ឋកម្ពុជាណាដែលមានសិទ្ធិបោះឆ្នោតគួរតែត្រូវបានផ្តល់សិទ្ធិដើម្បីស្នើសុំការចុះឈ្មោះជាមួយអាជ្ញាធរបោះឆ្នោត និង/ឬអាជ្ញាធរមូលដ្ឋាន នៅពេលណាមួយក្នុងអំឡុងឆ្នាំនោះ។ នៅពេលដែលប័ណ្ណត្រូវបានចេញឲ្យហើយនោះ វាគួរតែមានសុពលភាពពេញមួយជីវិត ប្រសិនបើមិនមានការផ្លាស់ប្តូរនូវស្ថានភាពផ្ទាល់ខ្លួនដែលតម្រូវឲ្យមានការកែប្រែនោះទេ"។ មួយវិញទៀត អ្នករាយការណ៍ពិសេសជឿថាកិច្ចការសំខាន់ៗដែលបានធ្វើរួចហើយដែលបម្រើដល់ការចុះឈ្មោះអ្នកបោះឆ្នោត គួរតែត្រូវបានប្រើប្រាស់ជាព័ត៌មាននៅរាល់ពេលបោះឆ្នោតម្តងៗ។ ថ្ងៃនេះ ខ្ញុំសង្ឃឹមថានឹងបានរៀនសូត្រពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពី ផែនការរបស់ខ្លួនក្នុងការធានាឲ្យបាននូវនិរន្តរភាពនៃដំណើរការចុះឈ្មោះបោះឆ្នោតថ្មី។

ដោយសារតែមិនមានប្រព័ន្ធណាមួយដែលល្អឥតខ្ចោះ ១០០% នោះ ការទាមទារឲ្យមានការឃ្លាំមើលឯករាជ្យមួយជានិច្ចកាលនឹងនៅតែជាតម្រូវការខ្ពស់ដដែល។ ប្រទេសកម្ពុជាទាមទារឲ្យមានសង្គមស៊ីវិលដ៏រស់រវើកមួយដែលមានសមត្ថភាព បំពេញតួនាទីនេះ។ ដើម្បីឲ្យសង្គមស៊ីវិលអាចធ្វើដូច្នេះបាន ដំណើរការចាំបាច់ត្រូវលម្អិត ចែករំលែកព័ត៌មាន។ បញ្ជីឈ្មោះបោះឆ្នោតពេញលេញចាំបាច់ត្រូវតែអាចចូលឆែកមើល ដោយអាចឲ្យមានការវិភាគ និងវាយតម្លៃបាន។ សេចក្តីព្រាងច្បាប់ និងវិធាននានាចាំបាច់ត្រូវចេញផ្សាយ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដោយត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ដែលអាចឲ្យមានការឆ្លុះបញ្ចាំងនូវគំនិតវែងឆ្ងាយ និងការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ។ ចាំបាច់ត្រូវមានការណែនាំច្បាស់លាស់អំពីរបៀបដែលត្រូវដោះស្រាយជម្លោះកើតមាននៅក្នុងដំណើរការចុះឈ្មោះអ្នកបោះឆ្នោត ដល់មន្ត្រីរៀបចំការបោះឆ្នោត, អ្នកឃ្លាំមើលការបោះឆ្នោត និងសាធារណជនទូទៅ។ មេរៀនពីការបោះឆ្នោតមុនៗស្តែងឲ្យឃើញនូវភាពចាំបាច់ក្នុងការធ្វើឲ្យប្រសើរឡើងជាដុំកំភួននូវភាពជឿទុកចិត្ត មិនត្រឹមតែទៅលើដំណើរការបោះឆ្នោតប៉ុណ្ណោះទេ ថែមទាំងទៅលើយន្តការដោះស្រាយជម្លោះជាប់ពាក់ព័ន្ធផ្សេងទៀតផងដែរ។

ឯកឧត្តម លោកលោកស្រី អ្នកនាងកញ្ញាជាទីគោរពរាប់អាន

កញ្ចក់ឆ្លុះសិទ្ធិមនុស្សតម្រូវឲ្យយើងពិចារណាទៅលើក្រុមគោលដៅជាក់លាក់ដែលគេងាយនឹងមើលរំលង ហើយជាញឹកញយត្រូវបានគេមើលរំលង រាប់ទាំងជនមានពិការភាព, ជនជាតិភាគតិច និងជនជាតិដើមភាគតិច, អនក្ខរជន និងជនគ្មានផ្ទះសម្បែង, ជនដែលត្រូវបានចាប់ និងឃុំខ្លួន ប៉ុន្តែមិនទាន់បានផ្តន្ទាទោស និងក្នុងចំណោមអ្នកដទៃផ្សេងទៀត។ តម្រូវការក្នុងការលើកស្ទួយការចូលរួមក្នុងនយោបាយរបស់ស្ត្រី ត្រូវបានផ្តោតយកចិត្តទុកដាក់ជាពិសេសនៅទូទាំងពិភពលោក ដែលត្រូវបានពង្រឹងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលទទួលយកជាសាកល។ មានសេចក្តីរាយការណ៍ជាច្រើនអំពីបំណងប្រាថ្នារបស់ប្រជាជនកម្ពុជាដែលរស់នៅបរទេសដែលចង់អនុវត្តនូវសិទ្ធិបោះឆ្នោតរបស់ពួកគេ។

មេរៀនមួយក្នុងចំណោមមេរៀនជាច្រើនក្នុងបទពិសោធន៍របស់អ៊ុនតាក់គឺថា ដំណើរមួយដែលមានការរាប់បញ្ចូលពិតប្រាកដគឺជាជាដំណើរការដែលអាចឈានដល់ជនទាំងឡាយដែលមិនស្ថិតនៅក្នុងការបញ្ជ្រាបនៃសង្គម មិនថាខាងរាងកាយ ឬសង្គមឡើយ ជាជាងដំណើរការដែលរំពឹងថាជនទាំងឡាយអាចរកផ្លូវដោយខ្លួនឯងបាន។ គុណភាព និងការឈានទៅដល់កិច្ចខិតខំប្រឹងប្រែងអប់រំប្រជាពលរដ្ឋនឹងមានសារៈសំខាន់ក្នុងការធ្វើឲ្យក្រុមទាំងនេះបានចូលរួម។ ការរៀបចំកំណែឯកសារនានាសម្រាប់ផ្សព្វផ្សាយជាសាធារណៈ បានបង្ហាញឲ្យឃើញថាមានប្រយោជន៍ ដូចជា ឯកសាររូបភាពពន្យល់ ការណែនាំផ្សេងៗ ដែលធ្វើឡើងដោយប្រើភាសាសាមញ្ញៗ និងកំណែឯកសារនានាសម្រាប់ជនពិការភ្នែក។

មានកិច្ចការជាច្រើនដែលទាមទាររៀបចំឲ្យបានជាមុនដើម្បីធានាថាសិទ្ធិបោះឆ្នោតត្រូវបានធានា និងមានវិធីជាច្រើនដែលសិទ្ធិនេះអាចធ្លាក់ចេញពីគន្លងផ្លូវ។ ខ្ញុំទន្ទឹងរង់ចាំស្តាប់មតិយោបល់របស់លោកអ្នកគ្រប់រូប និងចង់ឃើញប្រព័ន្ធបោះឆ្នោតមួយនៅក្នុងប្រទេសកម្ពុជារឹងមាំ។ ការចាប់ផ្តើមក្នុង "រដូវកាលថ្មីឆ្នាំ" នេះ ខ្ញុំសូមជូនពរឯកឧត្តម អស់លោកលោកស្រីអ្នកនាងកញ្ញាទាំងអស់ដោយស្មោះ សូមឲ្យទទួលបានសុភមង្គល ជោគជ័យ និងសេចក្តីសុខក្នុងឆ្នាំថ្មីនេះ និងសូមទទួលបានព្រះពុទ្ធពរទាំងបួនប្រការ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។